**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jun-2012, 13:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបរបស់លោក អៀង សារី ទៅកាន់សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូរ ឧត្តរ៉ា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង ធូ មណី

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ ("សំណើរបស់សហព្រះរាជអាជ្ញា"[1])។ សំណើនេះគឺចាំបាច់ដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា មេធាវីការពារក្តីមានបំណងជំទាស់ទៅនឹងចម្លើយជាច្រើនរបស់សាក្សីដែលដាក់ដោយព្រះរាជអាជ្ញាដោយផ្អែកលើមូលដ្ឋានថាចម្លើយទាំងនោះមានភាពច្រំដែល ខ្វះភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន ឬដោយសារតែច្បាប់មិនអនុញ្ញាតឲ្យទទួលយកចម្លើយបែបនេះ ។ មេធាវីការពារក្តីនឹងធ្វើដូច្នេះនៅពេលដែលសហព្រះរាជអាជ្ញាបានអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង និងនៅពេលដែលអង្គជំនុំជម្រះសាលាដំបូង បានកំណត់ពេលវេលាសម្រាប់ឲ្យមេធាវីការពារក្តីដាក់ការជំទាស់។ សំណើរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងដល់ភាគីមួយថ្ងៃមុនពេលដែលអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[2]។ តាមរយៈសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យភាគីទាំងអស់ដែលមានបំណងដាក់ចម្លើយសាក្សីនៅចំពោះមុខខ្លួនត្រូវ **ក.** ពិនិត្យមើលបញ្ជីឯកសាររបស់ពួកគេដើម្បីឲ្យស្របជាមួយនឹងលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបាននៃឯកសារដូចដែលបានកំណត់ដោយអង្គជំនុំជម្រះដំបូង **ខ.** បញ្ជាក់ពីគោលបំណងនៃភស្តុតាងរបស់ឯកសារនីមួយៗឲ្យបានច្បាស់លាស់ ឬប្រភេទនៃភស្តុតាងនីមួយៗដែលបានស្នើសុំ **គ.** ពិចារណាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះតែភស្តុតាងមួយសម្រាប់ជាគំរូដែលតំណាងឲ្យប្រភេទនៃភស្តុតាងនីមួយៗ ជាជាងដាក់រាល់ឯកសារទាំងអស់ដែលបានស្នើសុំ និង **ឃ.** ផ្តល់នូវការបញ្ជាក់ច្បាស់លាស់ខាងលើត្រឹមថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចកំណត់ពេលសវនាការ ឬអនុញ្ញាតឲ្យដាក់ការជំទាស់[3] ។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថាខ្លួន "នឹងកំណត់ពេលសវនាការនាពេលវេលាសមស្រប ឬក៏ផ្តល់ឱកាសឲ្យភាគីដាក់ការជំទាស់ដែលពាក់ព័ន្ធនឹងភស្តុតាង អនុលោមតាមវិធាន៨៧ (៣) នៃវិធានផ្ទៃក្នុង[4]"។ មេធាវីការពារក្តីស្នើ

---

[1] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២, ឯកសារ E208។

[2] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២, ឯកសារ E96/7។

[3] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៣៥។

[4] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៣៦។

សុំពេលវេលាឲ្យបានគ្រប់គ្រាន់ ដើម្បីរៀបចំការជំទាស់នេះនៅពេលដែលសហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសាររបស់ខ្លួនស្របតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ពេលវេលាគ្រប់គ្រាន់គឺមានសារៈសំខាន់ ជាពិសេសបើពិនិត្យទៅលើការពិតដែលថាសហព្រះរាជអាជ្ញាទំនងជាស្នើសុំឲ្យមានការទទួលយកចម្លើយរាប់រយរបស់សាក្សី (ដោយពិចារណាទៅលើមូលហេតុដែលថាក្នុងសំណើរបស់សហព្រះរាជអាជ្ញាតែឯង ការស្នើសុំឲ្យមានទទួលយកចម្លើយសាក្សីជាង១៧៥ត្រូវបានធ្វើឡើង) ហើយមេធាវីការពារក្តី ជាមួយនឹងការបំពេញកិច្ចការដោយយកចិត្តទុកដាក់ពិតប្រាកដចាំបាច់ត្រូវតែពិនិត្យមើលកំណត់ហេតុតាមវិច្ឆេកវិទ្យាសោទស្សន៍នៃចម្លើយសាក្សីទាំងនេះ ដើម្បីរកឲ្យឃើញពីភាពមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នានានារវាងកំណត់ហេតុ តាមរយៈប្រព័ន្ធសោតទស្សន៍ និងសេចក្តីសង្ខេបដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។

**ដូច្នេះ** សម្រាប់មូលហេតុដូចដែលបានរៀបរាប់ខាងលើនេះ មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ពេលវេលាឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យមេធាវីការពារក្តីអាចដាក់ការជំទាស់របស់ខ្លួនទៅនឹងចម្លើយសាក្សីដែលស្នើសុំដោយសហព្រះរាជអាជ្ញា នៅពេលដែលសហព្រះរាជអាជ្ញាបានអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង។

សូមលោក/លោកស្រីចៅក្រមទទួលយកសំណើនេះដោយក្តីគោរព

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៧** ខែ **មិថុនា** ឆ្នាំ **២០១២**

________________ ________________

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**